# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អគ្គលេខាធិការដ្ឋាន**
លេខ : ០៧១ គ.ជ.ប.អគ្គ

ថ្ងៃសៅរ៍ ១៥កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០២៣

## សេចក្ដីប្រកាសព័ត៌មាន
## គ.ជ.ប ជួបប្រជុំជាមួយគណបក្សនយោបាយ ដើម្បីរៀបចំកម្មវិធីផ្សព្វផ្សាយ គោលនយោបាយរបស់គណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

នៅរសៀលថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានជួបប្រជុំជាមួយតំណាងគណបក្សនយោបាយ ដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងការរៀបចំកម្មវិធីផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយ សម្រាប់ធ្វើការផ្សព្វផ្សាយក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។ កិច្ចប្រជុំនេះប្រព្រឹត្តទៅនៅទីស្ដីការ គ.ជ.ប ក្រោមអធិបតីភាពឯកឧត្ដម **ម៉ុក ដារ៉ា** អគ្គលេខាធិការរង គ.ជ.ប និងជាប្រធានគណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងកម្មវិធីផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយ ហៅកាត់ថា "គណៈកម្មការសម្របសម្រួល" និងមានការអញ្ជើញចូលរួមពីតំណាងគណបក្សនយោបាយដែលចូលរួមក្នុងការបោះឆ្នោត និងសមាជិកគណៈកម្មការសម្របសម្រួល។

ឯកឧត្ដម **ម៉ុក ដារ៉ា** អគ្គលេខាធិការរង គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំ បានមានប្រសាសន៍ថា គណៈកម្មការសម្របសម្រួល រៀបចំកិច្ចប្រជុំនេះ ដើម្បីជម្រាបជូនគណបក្សនយោបាយអំពីគោលការណ៍ ប្រធានបទ និងកិច្ចការបច្ចេកទេសមួយចំនួន ដើម្បីត្រៀមរៀបចំការផលិតកម្មវិធីផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយ (កម្មវិធីតុមូល) និងស្ប៉តឃោសនារបស់គណបក្សនយោបាយ ដែលត្រូវចាក់ផ្សាយនៅវិទ្យុជាតិ និងទូរទស្សន៍ជាតិកម្ពុជា រួមនឹងការរៀបចំអត្ថបទឃោសនារបស់គណបក្សនយោបាយនៅលើព្រឹត្តិបត្រគោលនយោបាយ ដែលចេញផ្សាយដោយ គ.ជ.ប ក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣។

ឯកឧត្ដម **ម៉ុក ដារ៉ា** បានបញ្ជាក់ថា សម្រាប់ការផ្សព្វផ្សាយខាងលើនេះ គណបក្សនយោបាយទាំងអស់ទទួលបានឱកាសដោយស្មើភាព តម្លាភាព និងឥតគិតថ្លៃ។ ក្នុងកិច្ចប្រជុំនេះ ឯកឧត្ដមប្រធានដឹកនាំកិច្ចប្រជុំ និងមន្ត្រីជំនាញ គ.ជ.ប បានធ្វើការបកស្រាយ ពន្យល់ និងឆ្លើយតបនឹងសំណួររបស់តំណាងគណបក្សនយោបាយ និងបានឱ្យតំណាងគណបក្សនយោបាយធ្វើការចាប់ឆ្នោត ដើម្បីឱ្យការផលិត ការថត និងការផ្សព្វផ្សាយកម្មវិធីផ្សព្វផ្សាយគោលនយោបាយ ស្ប៉តគណបក្សនយោបាយ និងព្រឹត្តិបត្រគោលនយោបាយ ប្រព្រឹត្តទៅដោយរលូន ស្របតាមនីតិវិធី និងមានតម្លាភាព។